ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ: ១០ /២០១៨ អ.កបធ.លស

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ ចាប់ពីម៉ោង ១០:០០ នាទី នៅសាលប្រជុំអគារ **ស** វិមានរដ្ឋចំការមន ក្រុមប្រឹក្សាធម្មនុញ្ញបានបើកកិច្ចប្រជុំពេញអង្គ ដើម្បីពិនិត្យនិងសម្រេចលើរបៀបវារៈ

១-ចុតហ្មាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ទូលថ្វាយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការស្នើសុំធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី។

២-បញ្ហាផ្សេងៗ

<u>ជាលទ្ធផលនៃកិច្ចប្រជុំនេះរួមមាន</u>:

១-ក្រុមប្រឹក្សាធម្មនុញ្ញបានអនុម័តជាឯកច្ឆន្ទដោយចំនួន ០៨ សម្លេង នៃចំនួនសមាជិកក្រុម-ប្រឹក្សាធម្មនុញ្ញទាំងមូល( អវត្តមាន០១អង្គ ដោយមូលហេតុប្រឈួន )ថាសេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា៣៤ថ្មី មាត្រា៤២ មាត្រា៤៩ មាត្រា៥៣ និងមាត្រា១១៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើទៅបាន។

២-ដោយឡែកបញ្ហាផ្សេងៗក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេច:

-បន្ថែមសមាសភាពអ្នកនាំពាក្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០២រូប គឺ:
ឯកឧត្តម **តាំង រតនា** និង ឯកឧត្តម **ព្រហ្ម វិចិត្ររង្សី**

-រៀបចំឯកសណ្ឋានសម្រាប់ប្រើក្នុងសវនាការជំនុំជម្រះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាប ។

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh ,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ